**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**អ.វ.ត.ក**



# សាលដីកាសង្ខេបរបស់អង្គជំនុំជម្រះតុលាការកំពូល
# ប្រកាសថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦

## សំណុំរឿង ០០២/០១
## នួន ជា និង ខៀវ សំផន

# សេចក្តីសង្ខេបនៃសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល
# លើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១

## ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦

1. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. បានចេញសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១ និងបានរកឃើញថា ជនជាប់ចោទ នួន ជា និង ខៀវ សំផន មានពិរុទ្ធភាពពីបទសម្លាប់រង្គាល (រួមបញ្ចូលបទមនុស្សឃាត) បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (មានដូចជា ការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស)។

2. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទឧក្រិដ្ឋទាំងនេះត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ចំនួន ៣ ដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០១ ដូចជា ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញភ្លាមៗបន្ទាប់ពីការដួលរលំទីក្រុងនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ (ហៅថា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ) ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដែលបានកើតឡើងពីចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៧ (ហៅថា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ) និងការសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃក្នុងខេត្តពោធិ៍សាត់នៅចុងខែ មេសា ឆ្នាំ ១៩៧៥។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា បើទោះបីជាជនជាប់ចោទទាំងពីរពុំបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយដោយផ្ទាល់ក៏ដោយ ក៏ជនជាប់ចោទត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងនេះ ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវដែលហៅថា "សហឧក្រិដ្ឋកម្មរួម" ព្រមទាំងដោយសារជនជាប់ចោទបានរៀបចំផែនការ ញុះញង់ ជួយនិងជំរុញ និង ចំពោះជនជាប់ចោទ នួន ជា តែម្នាក់ទាក់ទងទៅនឹងការបញ្ជានៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។

3. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចផ្តន្ទាទោសជនជាប់ចោទម្នាក់ៗដាក់ពន្ធនាគារអស់មួយជីវិត។ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកផ្នែកខ្លះនៃសំណើសុំទាមទារសំណងផ្លូវចិត្ត និងសមូហភាពដោយបានសម្រេចផ្តល់សំណងចំនួន ១១ ដល់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងបញ្ហានេះ។

4. នួន ជា និង ខៀវ សំផន ព្រមទាំងសហព្រះរាជអាជ្ញាបានដាក់សារណាបណ្តឹងសាទុក្ខ និងសារណាតបរៀងៗខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានដាក់សារណាជាលាយលក្ខណ៍អក្សរផងដែរ។ អង្គជំនុំជម្រះតុលាការកំពូលបានបើកសវនាការនៅថ្ងៃទី ០២ ទី ០៣ និង ទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ ដើម្បីសួរ

សាក្សីចំនួន ៣ រូបបន្ថែមទៀត។ នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និង ចាប់ពីថ្ងៃទី ១៦ ដល់ ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ អង្គជំនុំជម្រះតុលាការកំពូលបានបើកសវនាការស្ដាប់សារណាផ្ទាល់មាត់លើបណ្ដឹងសាទុក្ខ។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលបានចាប់ផ្ដើមពិភាក្សាសម្រេចលើបណ្ដឹងសាទុក្ខនេះ។

5. នៅថ្ងៃនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងចេញសាលដីកាពេញលេញលើបណ្ដឹងសាទុក្ខទាំងបី ដែលមានអានុភាពផ្លូវច្បាប់។ ដើម្បីជួយដល់សាធារណជនឱ្យយល់ច្បាស់អំពីការសម្រេចរបស់តុលាការ ខ្ញុំសូមសង្ខេបនូវសំអាងហេតុ និងផ្នែកសម្រេចសេចក្ដីរបស់អង្គជំនុំជម្រះតុលាការកំពូល ប៉ុន្តែសេចក្ដីសង្ខេបនេះ មិនមែនជាផ្នែកមួយនៃសំអាងហេតុសម្រាប់ការសម្រេចនេះឡើយ។

6. បណ្ដឹងសាទុក្ខរបស់ នួន ជា មានទទ្បីករណ៍ចំនួន ២២៣ ហើយ ខៀវ សំផន មានចំនួន ១៤៨ ដែលមានលក្ខណៈត្រួតគ្នាជាច្រើន។ ដោយសារមូលហេតុនេះ ខ្ញុំសូមសង្ខេបបណ្ដឹងសាទុក្ខទាំងពីរនេះរួមគ្នាដូចមាននៅក្នុងសាលដីកាពេញលេញ។ ចំពោះបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ខ្ញុំសូមសង្ខេបដាច់ដោយឡែក។

7. ខ្ញុំសូមបញ្ជាក់ថា ដោយសារទទ្បីករណ៍នៅក្នុងបណ្ដឹងសាទុក្ខមានចំនួនច្រើន ដូចនេះខ្ញុំសូមសង្ខេបចំពោះតែការយល់ឃើញទាក់ទងទៅនឹងទទ្បីករណ៍ណាដែលមានភាពចម្រូងចម្រាស ឬមានសារៈសំខាន់ ឬមានអត្ថប្រយោជន៍ចំពោះសាធារណជនប៉ុណ្ណោះ។ ជាក់ស្ដែង អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើទទ្បីករណ៍ទាំងអស់នៃបណ្ដឹងសាទុក្ខដែលបានលើកឡើងនោះ ហើយអង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់ការយល់ឃើញចំពោះទទ្បីករណ៍ទាំងនេះ នៅក្នុងសាលដីកាពេញលេញត្រឹមត្រូវជាលាយលក្ខណ៍អក្សររបស់ខ្លួន ដែលនឹងត្រូវជូនដំណឹងដល់ភាគីក្នុងពេលឆាប់ៗបន្ទាប់ពីសវនាការនេះត្រូវបានបញ្ចប់។

## ១.បណ្ដឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន

8. ទទ្បីករណ៍នៃបណ្ដឹងសាទុក្ខដែល នួន ជា និង ខៀវ សំផន បានលើកឡើង បានបែងចែកជាប្រាំប្រភេទជាក់លាក់ដូចខាងក្រោម៖

### ១.១.ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី

9. ជនជាប់ចោទបានលើកអំណះអំណាងមួយចំនួន ជំទាស់ទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីដែលបានអនុវត្តចំពោះពួកគាត់។ ក្នុងផ្នែកនេះ មានពីរចំណុចទាក់ទងទៅនឹងអំណះអំណាងនៃបណ្ដឹងសាទុក្ខនេះ។

### ១.១.១.សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឧក្រិដ្ឋកម្មឯករាជ្យឥតលម្អៀង

10. ជាការកត់សម្គាល់ ជនជាប់ចោទបានលើកឡើងថា សិទ្ធិរបស់ពួកគាត់ក្នុងការទទួលបានការជំនុំជម្រះនៅចំពោះមុខតុលាការឯករាជ្យឥតលម្អៀង ត្រូវបានរំលោភបំពាន។

11. អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងដែលបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀងតាមរយៈអ្វីដែលបានបង្ហាញឱ្យឃើញ ដូចជាការយល់ឃើញពុំត្រឹមត្រូវ និងមានកំហុសនោះ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា តាមរយៈកិច្ចសម្ភាសន៍របស់លោកស្រីចៅក្រម Cartwright ក្នុងឆ្នាំ ២០១៣ ពុំបានបង្ហាញថា លោកស្រីមានភាពលម្អៀងឡើយ។ ចំពោះអំណះអំណាងអំពីកង្វះឯករាជភាព ដោយផ្អែកលើការលើកឡើងនៅក្នុងសៀវភៅរបស់អតីតសហចៅក្រមស៊ើបអង្កេត Marcel LEMONDE អង្គជំនុំជម្រះកត់សម្គាល់ថា មតិយោបល់ទាំងនោះ គឺគ្រាន់តែជាលក្ខណៈទូទៅ ហើយមិនជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ នោះទេ។ ទាក់ទងទៅនឹងការចោទប្រកាន់របស់ ថេត សម្បត្តិ ដែលថា សាក្សីសក្ខានុពលពុំបានមកផ្ដល់សក្ខីកម្មដោយសារបារម្ភពីសន្តិសុខនោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា បើទោះបី នេះជាការចោទប្រកាន់គួរឱ្យជឿក៏ដោយ ក៏ការចោទប្រកាន់នេះពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហាដែលថា អង្គជំនុំជម្រះសាលាដំបូងខ្វះឯករាជភាពនោះដែរ។ ចំពោះអំណះអំណាងដែលថា សំអាងហេតុរបស់ចៅក្រមជាតិសម្រេចមិនកោះហៅ ហេង សំរិន មកធ្វើជាសាក្សី បានបង្ហាញអំពីកង្វះឯករាជភាពនោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ពុំមានភាពច្បាស់លាស់ក្នុងការសន្និដ្ឋានបានយ៉ាងដូច្នោះឡើយ ព្រោះសក្ខីកម្មដែលរំពឹងទុកនោះអាចពុំមានការជាប់ពាក់ព័ន្ធ។

### ១.១.២.សិទ្ធិទទួលបានការការពារខ្លួនដោយប្រសិទ្ធភាព

12. នួន ជា និង ខៀវ សំផន បានលើកទឡ្ហីករណ៍មួយចំនួនដើម្បីគាំទ្រអំណះអំណាងដែលថា សិទ្ធិរបស់ពួកគាត់ក្នុងការទទួលបានការការពារដោយប្រសិទ្ធភាពត្រូវបានរំលោភបំពាន ដែលមានដូចជាការសម្រេចមិនកោះហៅសាក្សីមួយចំនួន។

13. ទាក់ទងទៅនឹងសាក្សី ហេង សំរិន ដែល នួន ជា បានស្នើសុំជាច្រើនដងឱ្យកោះហៅសាក្សីរូបនេះមកផ្ដល់សក្ខីកម្ម ដែលក្នុងនោះ ក៏មាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងផងដែរ។ អង្គជំនុំជម្រះសាលាដំបូងពុំអាចទទួលបានមតិភាគច្រើនលើសលុបសម្រាប់ការកោះហៅសាក្សី ហេង សំរិន មកធ្វើសក្ខីកម្មបានឡើយ។ បើទោះបីជាចៅក្រមបីរូបបានយល់ឃើញថា ការកោះហៅនេះពុំមានភាពចាំបាច់

ក៏ដោយ ក៏ចៅក្រមពីររូបទៀតបានយល់ឃើញថា សាក្សី ហេង សំរិន គឺជាសាក្សីពាក់ព័ន្ធដែលគប្បីកោះហៅ។

14. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងសាក្សី ហេង សំរិន ពុំមានលក្ខណៈសមហេតុផលនោះទេ។ ជាការកត់សម្គាល់ ចៅក្រមបីរូបដែលបានយល់ឃើញថា សាក្សី ហេង សំរិន ពុំគប្បីកោះហៅនោះ បានបញ្ជាក់ថា ការកោះហៅនេះអាចបណ្តាលឱ្យមានការពន្យារពេលយ៉ាងច្រើន។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នេះគឺជាកំហុស ព្រោះតាមកំណត់ត្រាកន្លងមក ពុំមានការបង្ហាញថា សាក្សី ហេង សំរិន បានបដិសេធក្នុងការចូលខ្លួនមកផ្តល់សក្ខីកម្មឡើយ ប្រសិនបើមានការកោះហៅនោះ។ បន្ថែមលើនេះទៀត សំណើសុំកោះហៅសាក្សី ហេង សំរិន បានធ្វើឡើងតាំងពីដំណាក់កាលដំបូងនៃកិច្ចដំណើរការនីតិវិធី ហើយប្រសិនបើមានបញ្ហាអ្វីកើតមានមែនក៏ដោយ ក៏មិនបានបង្ហាញឱ្យឃើញថា ត្រូវបានដោះស្រាយនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ។

15. អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ការសន្និដ្ឋានដូចខាងលើនេះទាក់ទងទៅនឹងសាក្សី អ៊ុក ប៊ុនឈឿន ដែល នួន ជា ក៏បានស្នើសុំឱ្យសាក្សីរូបនេះមកផ្តល់សក្ខីកម្មផងដែរ។

16. ទាក់ទងទៅនឹងបញ្ហាបន្ទាប់ដែលអង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយគឺ ថាតើជនជាប់ចោទជាក់ស្តែងបានទទួលរងផលប៉ះពាល់ដោយសារកំហុសរបស់អង្គជំនុំជម្រះសាលាដំបូង ដែរ ឬយ៉ាងណា។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សាក្សីទាំងពីររូបនេះ ទំនងជាមានព័ត៌មានដោះបន្ទុកជាសក្តានុពលដូចសាក្សីដទៃទៀតដែរ។ ចំពោះការបញ្ជាក់នៅក្នុងបទសម្ភាសន៍របស់ ហេង សំរិន ពីដំបូងដែលបានធ្វើឡើងទាក់ទងទៅនឹងគោលនយោបាយរបស់ខ្មែរក្រហមទៅលើទាហាននៃរបបសាធារណរដ្ឋខ្មែរ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា កំណត់ត្រានៃបទសម្ភាសន៍នេះ ពិតជាបានបង្ហាញអំពីបញ្ហាដែលអាចបំភ្លឺតាមរយៈសក្ខីកម្មនេះបាន។ ទោះជាយ៉ាងនេះក្តី កំណត់ត្រានៃបទសម្ភាសន៍នេះ មាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរួចហើយ និងអាចយកមកពិចារណាបាន។ សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានការបង្ហាញថា ការសម្រេចមិនកោះហៅសាក្សី ហេង សំរិន និង អ៊ុក ប៊ុនឈឿន បានបណ្តាលឱ្យមាន "លទ្ធផលខុសឆ្គងធ្ងន់ធ្ងរនៅក្នុងកិច្ចដំណើរការនីតិវិធី" ដែលតម្រូវឱ្យបដិសេធការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទឡើយ។

17. ជនជាប់ចោទបានលើកបញ្ហាជាច្រើនទៀតទាក់ទងទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី និងបាន អះអាងអំពីអធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុងផងដែរ។ ដោយបានពិចារណាលើសារណារបស់ភាគី អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធអំណះអំណាងទាំងអស់នោះ ដោយផ្អែកលើសំអាងហេតុដែលបានរៀបរាប់នៅក្នុងសាលដីកាពេញលេញ។

## ១.២.វិធីសាស្ត្រទទួលយកភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង

18. នេះជាផ្នែកទីពីរអំពីទឡ្ហីករណ៍នៅក្នុងបណ្តឹងសាទុក្ខទាក់ទងទៅនឹងវិធីសាស្ត្រទទួលយកភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង និងរំឭកថា ការសង្ខេបនេះកម្រិតត្រឹមតែបញ្ហាមួយចំនួនដែលសំខាន់បំផុតប៉ុណ្ណោះ។

### ១.២.១.ការកម្រិតឱកាសសម្រាប់ការស៊ើបសួរក្នុងពេលជំនុំជម្រះ

19. ជនជាប់ចោទបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានកម្រិតឱកាសសម្រាប់ការស៊ើបសួរក្នុងពេលជំនុំជម្រះ។

20. បញ្ហាទីមួយគឺ ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបញ្ជាក់ថា ភាគីការពារក្តីពុំមានសិទ្ធិធ្វើការស៊ើបសួរ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បើទោះបីជាក្របខ័ណ្ឌផ្នែកនីតិវិធីរបស់ អ.វ.ត.ក. ពុំបានចែងអំពីការស៊ើបសួរពេញលេញដែលត្រូវធ្វើឡើងដោយភាគីការពារក្តីក៏ដោយ ក៏ពុំមានមូលដ្ឋាននៃលក្ខន្តិកៈ ឬហេតុផលជាក់ស្តែងណាមួយដែលគួរឱ្យជឿជាក់ បានហាមឃាត់ភាគីការពារក្តីក្នុងការបើកកិច្ចស៊ើបសួរក្រោមលក្ខខណ្ឌមួយចំនួន ក្នុងគោលបំណងស្វែងរកភស្តុតាងពាក់ព័ន្ធនោះឡើយ ជាពិសេស ក្នុងការអនុញ្ញាតឲ្យភាគីការពារក្តីអាចធ្វើសំណើដល់អង្គភាពនានារបស់ អ.វ.ត.ក.ឲ្យបើកការស៊ើបសួរបន្ថែម។

21. បញ្ហាទីពីរគឺ ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការសម្រេចលើសំណើសុំបើកកិច្ចស៊ើបសួរ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា វិធីសាស្ត្រទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈសមហេតុផល និងថា ភាពខុសឆ្គងផ្នែកនីតិវិធីណាមួយក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ត្រូវបានដោះស្រាយរួចហើយ តាមរយៈដីកាដំណោះស្រាយ ។

### ១.២.២.ការអនុញ្ញាតឱ្យសាក្សីពិនិត្យចម្លើយពីមុនរបស់ខ្លួនដើម្បីបញ្ជាក់ខ្លឹមសារ

22. បញ្ហាបន្ទាប់គឺ ពាក់ព័ន្ធទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលអនុញ្ញាតឱ្យសាក្សីពិនិត្យចម្លើយពីមុនរបស់ខ្លួននៅមុនពេលសាក្សីចូលមកផ្តល់សក្ខីកម្ម។

23. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការអនុម័តយកនីតិវិធីបែបនោះ បានធ្វើឱ្យមានភាពមិនស៊ីសង្វាក់គ្នាជាមួយការអនុវត្តរបស់កម្ពុជា។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុងកាលៈទេសៈនៃរឿងក្តីនេះឡើយ។

## ១.២.៣.ការទទួលយក និងការប្រើប្រាស់ភស្តុតាងជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់

24. ជនជាប់ចោទបានជំទាស់ទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ក្នុងកាលៈទេសៈមួយចំនួន ភស្តុតាងក្នុងទម្រង់ជាចម្លើយលាយលក្ខណ៍អក្សរ ឬប្រតិចារឹក អាចទទួលយកបាន បើទោះបីជាភាគីការពារក្តីពុំមានឱកាសសួរដេញដោលសាមីជនជាម្ចាស់ចម្លើយនេះក៏ដោយ។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងបានទទួលយកចម្លើយ និងប្រតិចារឹកជាលាយលក្ខណ៍អក្សរចំនួន ១.១២៤។

25. ដំបូង អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សិទ្ធិក្នុងការសួរដេញដោលសាក្សី ពុំមានលក្ខណៈដាច់ខាតនោះឡើយ។ ការផ្តល់សិទ្ធិទូលំទូលាយគ្មានកម្រិតក្នុងការសួរសាក្សីប្រឆាំងនឹងជនជាប់ចោទ អាចមានហានិភ័យប៉ះពាល់ដល់លទ្ធភាពរបស់តុលាការក្នុងការផ្តល់យុត្តិធម៌នៅក្នុងរឿងក្តីមួយ ដែលមានទំហំធំធេង និងមានភាពស្មុគស្មាញដូចរឿងក្តីបច្ចុប្បន្ននេះ។

26. ទីពីរ ជនជាប់ចោទបានជំទាស់ទៅនឹងទម្ងន់ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ទៅលើចម្លើយជាលាយលក្ខណ៍អក្សរ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ចម្លើយជាលាយលក្ខណ៍អក្សរជាទូទៅត្រូវតែផ្តល់តម្លៃជាភស្តុតាងក្នុងកម្រិតទាប ដោយសារភាគីពុំបានសួរដេញដោលសាក្សីដែលបានផ្តល់ចម្លើយនេះ។ អង្គជំនុំជម្រះសាលាដំបូងពិតជាបានបញ្ជាក់ថា អង្គជំនុំជម្រះបានពិចារណាលើគោលការណ៍នេះនៅក្នុងការវាយតម្លៃភស្តុតាង ដូច្នេះពុំមានកំហុសពាក់ព័ន្ធនឹងបញ្ហានេះឡើយ។ ទោះជាយ៉ាងណាក្តី បញ្ហាដែលកាន់តែស្មុគស្មាញជាងនេះគឺ ថាតើអង្គជំនុំជម្រះសាលាដំបូងបានសំអាងយ៉ាងខ្លាំងទៅលើចម្លើយក្រៅតុលាការ ដែរ ឬយ៉ាងណា ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់ខ្លួននោះ។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើបញ្ហានេះទាក់ទងទៅនឹងការយល់ឃើញជាក់លាក់នោះ។

## ១.២.៤.ការសំអាងទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

27. ទឡ្ហីករណ៍បន្ទាប់ដែលត្រូវលើកឡើង គឺពាក់ព័ន្ធទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងដែលបានផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើ

អំណះអំណាងដែលបានលើកឡើងដោយជនជាប់ចោទ ទាក់ទងទៅនឹងបញ្ហានេះឡើយ។ ដំបូង បើទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិពិសេសនៅក្នុងកិច្ចដំណើរការនីតិវិធីក៏ដោយ ក៏នេះពុំមែនមានន័យថា ដើមបណ្តឹងរដ្ឋប្បវេណីពុំអាចផ្តល់សក្ខីកម្មបាននោះដែរ។ ទម្ងន់ដែលបានផ្តល់ទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវវាយតម្លៃដោយផ្អែកលើករណីជាក់ស្តែងនីមួយៗ ដោយពិចារណារួមគ្នាផងដែរជាមួយនឹងបញ្ហាដែលថា ដើមបណ្តឹងរដ្ឋប្បវេណីពុំបានតម្រូវឱ្យធ្វើសម្បថនោះ។

28. បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការសំអាងទៅលើសេចក្តីថ្លែងអំពីទុក្ខសោក ឬសក្ខីកម្មអំពីផលប៉ះពាល់របស់ជនរងគ្រោះ ដោយសារមានការបង្ហាញច្បាស់លាស់ថា ទាំងនេះអាចមានព័ត៌មានមួយចំនួនពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ។

29. ជនជាប់ចោទបានលើកអំណះអំណាងមួយចំនួនផ្សេងទៀតទាក់ទងទៅនឹងវិធីសាស្ត្រទទួលយកភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង ដូចជា ការសំអាងទៅលើសាក្សីជំនាញ និងការអនុវត្តមួយចំនួននៅក្នុងបន្ទប់សវនាការនៅពេលសាក្សីនេះត្រូវបានស្នើសុំឱ្យផ្តល់យោបល់លើឯកសារ។ អំណះអំណាងទាំងអស់នេះ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលវាយតម្លៃដោយប្រុងប្រយ័ត្ន ហើយបានផ្តល់ការយល់ឃើញរបស់ខ្លួននៅក្នុងសាលដីកាពេញលេញ។ ខាងក្រោមនេះ ជាការយល់ឃើញអំពីខ្លឹមសារនៃសំណុំរឿងពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាព។

### **១.៣.ការយល់ឃើញពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាព**

30. ដូចបានលើកឡើងពីដំបូង បទចោទនៅក្នុងសំណុំរឿង ០០២/០១ ជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលបានចោទប្រកាន់នៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ចំនួន ៣ គឺ ការជម្លៀសចេញពីទីក្រុងភ្នំពេញ សំដៅលើការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ការផ្លាស់ទីលំនៅប្រជាជនដែលចាប់ផ្តើមនៅពាក់កណ្តាលចុងក្រោយក្នុងឆ្នាំ ១៩៧៥ រហូតដល់ក្នុងឆ្នាំ ១៩៧៧ ហៅថា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ និងការសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា មានការប្រព្រឹត្តបទឧក្រិដ្ឋមួយចំនួននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ទាំងនេះ។ ដូចបានលើកឡើងខាងលើ ជនជាប់ចោទទាំងពីរពុំបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះដោយផ្ទាល់នោះទេ។ យោងតាមអង្គជំនុំជម្រះសាលាដំបូង បើទោះបីជាបទឧក្រិដ្ឋទាំងនេះត្រូវបានប្រព្រឹត្តឡើងដោយខ្មែរក្រហមដទៃទៀតក៏ដោយ ក៏ជនជាប់ចោទទាំងពីរត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះដែរ។

31. ជាលទ្ធផល ការពិចារណាអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទអាចត្រូវបានបែងចែកជាពីរយ៉ាងទូលំទូលាយគឺ ទីមួយ បទឧក្រិដ្ឋជាក់ស្តែងដែលខ្មែរក្រហមបានប្រព្រឹត្ត និងទីពីរ ថាតើជនជាប់ចោទអាចត្រូវដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងនេះបាន ដែរ ឬយ៉ាងណា។

## ១.៣.១.ការធ្វើមនុស្សឃាត

### ១.៣.១.១.ការកំណត់និយមន័យធាតុផ្សំអត្តនោម័តនៃបទមនុស្សឃាត

32. ទាក់ទងទៅនឹងបទមនុស្សឃាត បញ្ហាទីមួយដែលត្រូវលើកឡើងចំពោះអង្គច្បាប់គឺ ការកំណត់និយមន័យនៃធាតុផ្សំអត្តនោម័ត។ ជនជាប់ចោទបានលើកឡើងថា លក្ខខណ្ឌនៃអំពើមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ កំណត់ថា ចារីបានប្រព្រឹត្តដោយចេតនាផ្ទាល់ក្នុងការធ្វើមនុស្សឃាត ក្នុងន័យថា គោលបំណងរបស់ចារីគឺ ធ្វើឱ្យជនដទៃទៀតស្លាប់។ មានការលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់និយមន័យធាតុផ្សំអត្តនោម័ត ពីព្រោះបានរួមបញ្ចូលការធ្វើមនុស្សឃាតដោយប្រយោល (Reckless Murder) ឬបើតាមពាក្យពេចន៍ក្នុងច្បាប់ស៊ីវិល មនុស្សឃាត *ដោយប្រយោល (dolus eventualis)*។

33. បន្ទាប់ពីបានពិនិត្យលើយុត្តិសាស្ត្រពាក់ព័ន្ធ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសទាក់ទងទៅនឹងបញ្ហានេះទេ។ អាស្រ័យហេតុនេះ ក៏អាចដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌពីបទមនុស្សឃាតបានដែរ បើទោះបីជាចារីពុំមានចេតនាផ្ទាល់ក៏ដោយ។

### ១.៣.១.២.កំហុសផ្នែកអង្គហេតុទាក់ទងទៅនឹងអំពើមនុស្សឃាត

34. ទឡ្ហីករណ៍ដទៃទៀតនៃបណ្តឹងសាទុក្ខគឺ ជាប់ពាក់ព័ន្ធជាចម្បងទៅនឹងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងអំពីហេតុការណ៍នៃការធ្វើមនុស្សឃាត ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយគឺ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងហេតុការណ៍នៃការធ្វើមនុស្សឃាតនៅទួលពោធិ៍ជ្រៃ។

35. ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយលើបញ្ហា ថាតើអង្គជំនុំជម្រះសាលាដំបូង ត្រូវបង្ហាញអំពីហេតុការណ៍នីមួយៗនៃការសម្លាប់ឱ្យហួសពីវិមតិសង្ស័យ ដែរ ឬយ៉ាងណា ដែលជាសំណួរមួយត្រូវបានអង្គជំនុំជម្រះតុលាការកំពូលឆ្លើយតបជាវិជ្ជមាន។ អាស្រ័យហេតុនេះ ដើម្បីបង្ហាញថា ខ្មែរក្រហមបានប្រព្រឹត្តអំពើមនុស្សឃាតនោះ ដែលករណីនៃការសម្លាប់នីមួយៗត្រូវតែបង្ហាញឱ្យហួសពីវិមតិសង្ស័យ។

36. ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យដោយប្រុងប្រយ័ត្នលើការយល់ឃើញផ្នែកអង្គហេតុដែលជនជាប់ចោទបានជំទាស់។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការយល់ឃើញមួយចំនួនអំពីការសម្លាប់ ពុំត្រូវបានបង្ហាញដោយសមហេតុផល ព្រោះជាចម្បងបានផ្អែកលើភស្តុតាងក្រៅតុលាការ ឬភស្តុតាងដែលពុំមានតម្លៃគ្រប់គ្រាន់។ ទោះជាយ៉ាងណាក្តី មានករណីមួយចំនួនទាក់ទងនឹងការសម្លាប់ត្រូវបានបង្ហាញដោយសមហេតុផល ផ្អែកលើភស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ អាស្រ័យហេតុនេះ ជាការសមហេតុផលក្នុងការសន្និដ្ឋានថា បទមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ។

## ១.៣.២.ការសម្លាប់រង្គាល

37. ទាក់ទងទៅនឹងបទសម្លាប់រង្គាល មានទទ្ទីករណ៍ជាច្រើននៃបណ្តឹងសាទុក្ខ ជាប់ពាក់ព័ន្ធទៅនឹងការកំណត់និយមន័យច្បាស់លាស់នៃបទឧក្រិដ្ឋនេះ។ ទីមួយ ជនជាប់ចោទបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សម្រាប់ធាតុផ្សំអត្តនោម័តនៃបទឧក្រិដ្ឋនេះ ការបង្ហាញឱ្យឃើញពី *ចេតនាប្រយោល* គឺជាការគ្រប់គ្រាន់។

38. អំណះអំណាងនេះមានមូលដ្ឋានត្រឹមត្រូវ។ បន្ទាប់ពីពិនិត្យលើយុត្តិសាស្ត្រពាក់ព័ន្ធ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខុសប្លែកពីបទមនុស្សឃាត បទសម្លាប់រង្គាលតម្រូវឱ្យមានការបង្ហាញអំពី *ចេតនាផ្ទាល់*ក្នុងការសម្លាប់ទ្រង់ទ្រាយធំ។ ដូច្នេះ ការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងអំពីធាតុផ្សំអត្តនោម័តនៃបទសម្លាប់រង្គាល មានលក្ខណៈពុំត្រឹមត្រូវដោយផ្នែក។

39. ជនជាប់ចោទបានលើកឡើងផងដែរថា នៅក្នុងព្រឹត្តិការណ៍នានា ក៏មានប្រជាជនជាច្រើនបានស្លាប់ផងដែរ និងថា ពុំមានការបង្ហាញថា ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ចំនួននៃការស្លាប់លើសអត្រាមរណភាពធម្មតាឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនេះ ដោយហេតុថា តាមការបញ្ជាក់របស់តុលាការ ICTY ប្រសិនបើចារីបង្កព្យសនកម្មដល់ជនរងគ្រោះ នោះចារីជាអ្នកទទួលខុសត្រូវចំពោះជនរងគ្រោះ។

40. អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាការពុំសមហេតុផលក្នុងការសន្និដ្ឋានថា ធាតុផ្សំសត្យានុម័តអំពី“ទំហំធំ”នៃបទសម្លាប់រង្គាលត្រូវបានបង្ហាញថា មានអត្ថិភាពទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ។ ដោយផ្អែកលើភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង មានតែការស្លាប់មួយចំនួនតូចប៉ុណ្ណោះដែលអាចចាត់ទុកថា ត្រូវបានបង្ហាញ

ហួសពីវិមតិសង្ស័យ។ ដោយសារភស្តុតាងខ្សោយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទើបពុំអាចសន្និដ្ឋានបានថា ការសម្លាប់បានកើតឡើងក្នុងទ្រង់ទ្រាយធំឡើយ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសញ្ញាណ *ចេតនាប្រយោល (dolus eventualis)* ដូចបានពន្យល់ខាងលើ ដែលនេះពុំមានលក្ខណៈគ្រប់គ្រាន់សម្រាប់បទសម្លាប់រង្គាលឡើយ។

41. ចំពោះការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា មានហេតុការណ៍នៃការសម្លាប់មួយចំនួនត្រូវបានបង្ហាញដោយសមហេតុផល។ ទោះជាយ៉ាងណាក្តី ពុំមានភស្តុតាងគ្រប់គ្រាន់ដែលអាចឱ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានដោយសមហេតុផលថា ការធ្វើមនុស្សឃាតបានកើតឡើងក្នុងទ្រង់ទ្រាយធំ ដូចលក្ខខណ្ឌតម្រូវនៃការសម្លាប់រង្គាលឡើយ។ បន្ថែមលើនេះទៀត ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញថា ចារីបានប្រព្រឹត្តដោយចេតនាផ្ទាល់ក្នុងការសម្លាប់ទ្រង់ទ្រាយធំ ប៉ុន្តែបានបញ្ជាក់ថា ចារីបានប្រព្រឹត្តដោយ *ចេតនាប្រយោល* (*dolus eventualis*) ដូចបានកត់សម្គាល់ខាងលើ ដែលនេះពុំមានលក្ខណៈគ្រប់គ្រាន់សម្រាប់បទសម្លាប់រង្គាលនោះទេ។

42. យោងតាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា បទសម្លាប់រង្គាលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ។

43. ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ អង្គជំនុំជម្រះបានយល់ស្របថា មានបទមនុស្សឃាតត្រូវបានប្រព្រឹត្តឡើង។ ទាក់ទងទៅនឹងដំណាក់កាលទីពីរ បើទោះបីជាបទសម្លាប់រង្គាលពុំត្រូវបានប្រព្រឹត្តឡើងក៏ដោយ ក៏អង្គហេតុដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា មានអត្ថិភាព និងទទួលស្គាល់នៅដំណាក់កាលបណ្តឹងសាទុក្ខនេះ បានបំពេញតាមលក្ខខណ្ឌធាតុផ្សំទាំងអស់នៃបទមនុស្សឃាតដែរ អាស្រ័យហេតុនេះ អង្គជំនុំតុលាការកំពូលសម្រេចដាក់ពិរុទ្ធភាពផ្អែកលើមូលដ្ឋាននេះ។

44. ទាក់ទងទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ជនជាប់ចោទបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា យ៉ាងហោចណាស់ មានទាហានចំនួន ២៥០ នាក់នៃរបបសាធារណរដ្ឋខ្មែរត្រូវបានសម្លាប់ក្នុងខែ មេសា ឆ្នាំ ១៩៧៥។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងទាំងនេះឡើយ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញចំនួន*អប្បបរមា*នៃការស្លាប់ ដោយ

ស្របតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*។ ដូចគ្នានេះដែរ មានភាពច្បាស់លាស់ថា ករណីនេះ ចារីបានប្រព្រឹត្តដោយចេតនាផ្ទាល់ក្នុងការសម្លាប់ទ្រង់ទ្រាយធំ។

45. សរុបសេចក្តីមក ការស្លាប់ និងការសម្លាប់ដែលបានកើតឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ ត្រូវចាត់ជាបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ចំណែកការសម្លាប់នៅទួលពោធិ៍ជ្រៃ ត្រូវចាត់ជាអំពើសម្លាប់រង្គាល។

### ១.៣.៣.អំពើអមនុស្សធម៌ផ្សេងៗទៀត

46. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ ពិតជាមានការប្រព្រឹត្តអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់នៃការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ បទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងក្រោមទម្រង់នៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ។

#### ១.៣.៣.១.វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងទៅលើបទអំពើអមនុស្សធម៌ផ្សេងៗទៀត

47. ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ធ្វើឱ្យមានការភាន់ច្រឡំត្រង់ថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យនៃធាតុផ្សំការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ហាក់បីដូចជាមានអត្ថិភាពក្នុងប្រភេទបទឧក្រិដ្ឋដាច់ដោយឡែកពីគ្នា។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងគប្បីផ្តោតលើបញ្ហា ថាតើនៅពេលពិចារណាជារួម អំពើប្រព្រឹត្តនេះមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋដទៃទៀតដែលបានទទួលស្គាល់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា។ បញ្ហានេះតម្រូវឱ្យមានការពិចារណាជារួម និងលើករណីជាក់លាក់នីមួយៗ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានធ្វើឡើងទៅលើបណ្តឹងសាទុក្ខ។

#### ១.៣.៣.២. កាលៈទេសៈក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងអនីត្យានុកូលភាពនៃការផ្លាស់ទីលំនៅនេះ

48. ជនជាប់ចោទ បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងលក្ខខណ្ឌ និងការប្រើប្រាស់អំពើហិង្សា ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាទូទៅ ការយល់ឃើញមានលក្ខណៈសមហេតុផល

បើទោះបីជាការយល់ឃើញទូទៅមួយចំនួនពុំសមហេតុផល និងពុំមានភស្តុតាងគាំទ្រគ្រប់គ្រាន់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក៏ដោយ។

49. អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់ទាក់ទងទៅនឹងការធ្វើយុត្តិកម្មចំពោះការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ជាទូទៅ អំណះអំណាងរបស់ជនជាប់ចោទបានបង្ហាញត្រឹមតែជាជម្រើសនៃការបកស្រាយអំពីភស្តុតាងប៉ុណ្ណោះ ដែលនេះជាការពុំសមហេតុផលឡើយ។

## ១.៣.៣.៣.កាលៈទេសៈក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ និងអនីត្យានុកូលភាពនៃការផ្លាស់ទីលំនៅនេះ

50. ជនជាប់ចោទបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ទាក់ទងទៅនឹងបញ្ហានេះ ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ រួមមានការផ្លាស់ទីលំនៅប្រជាជននៅក្នុងផ្នែកផ្សេងៗនៃប្រទេសកម្ពុជា និងក្នុងរយៈពេលយូរ។ ផ្អែកលើអង្គហេតុនេះ ការយល់ឃើញទូទៅមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូងពុំមានលក្ខណៈសមហេតុផល ដោយសារបានផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលមានកម្រិតខ្សោយ។ ទោះជាយ៉ាងណាក្តី ជាការសមហេតុផលក្នុងការយល់ឃើញថា ជាទូទៅការខ្វះស្បៀងអាហារ ទឹក សម្ភារអនាម័យ ព្រមទាំងការខ្វះថ្នាំពេទ្យ និងជំនួយផ្នែកវេជ្ជសាស្ត្រ និងមានភស្តុតាងគ្រប់គ្រាន់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងការយល់ឃើញថា ប្រជាជនមួយចំនួនត្រូវបានបាត់ខ្លួន និងប្រជាជនដទៃទៀតបានស្លាប់ដោយសារលក្ខខណ្ឌនៃការផ្លាស់ទីលំនៅនេះ។ ផ្ទុយទៅវិញ ជាការពុំសមហេតុផលក្នុងការយល់ឃើញដែលថា “ប្រជាជនភាគច្រើនលើសលុប”ដែលត្រូវបានជម្លៀសនោះជា“ប្រជាជនថ្មី” ដែលជាអតីតអ្នកទីក្រុង ដោយសារមានភស្តុតាងបង្ហាញឱ្យឃើញថាទាក់ទងទៅនឹងការផ្លាស់ទីលំនៅនេះ ក៏មាន“ប្រជាជនចាស់”ផងដែរ។

## ១.៣.៣.៤.ថាតើការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ ត្រូវចាត់ជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងកាលៈទេសៈនេះ ដែរ ឬយ៉ាងណា

51. ដូចបានលើកឡើងខាងលើ អាស្រ័យលើអង្គជំនុំជម្រះតុលាការកំពូលក្នុងការវាយតម្លៃលើបញ្ហា ថាតើការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ ត្រូវចាត់ជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា។

52. ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា មានការបង្ហាញឱ្យឃើញថា យ៉ាងហោចណាស់មានប្រជាជនចំនួន ២ លាននាក់ ត្រូវបានផ្លាស់ទីលំនៅដោយបង្ខំចេញពីទីក្រុងភ្នំពេញដោយគ្មានការជូនដំណឹងជាមុន និងក្រោមកាលៈទេសៈគួរឱ្យភ័យខ្លាច និងហិង្សា។ មានការបង្ហាញផងដែរថា ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន មានការសម្លាប់ និងការស្លាប់ដោយសារលក្ខខណ្ឌដែលបានបង្កទៅលើប្រជាជន។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ក្នុងកាលៈទេសៈនេះ ការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញបានបង្កឱ្យមានការរងទុក្ខ និងព្យសនកម្មធ្ងន់ធ្ងរផ្នែករូបកាយ និងផ្លូវចិត្ត និងធ្វើឱ្យប៉ះពាល់ដល់ប្រជាជនជាច្រើននាក់។ អាស្រ័យហេតុនេះ នេះគឺជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

53. ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ យ៉ាងហោចណាស់ មានប្រជាជនពី ៣០០.០០០ ទៅ ៤០០.០០០ នាក់ត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅ។ ការយល់ឃើញនេះត្រូវចាត់ទុកជាបានការនៅដំណាក់កាលបណ្តឹងសាទុក្ខ។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលទទួលយកការយល់ឃើញដែលថា ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅទាំងនោះ បានទទួលរងនូវលក្ខខណ្ឌធ្ងន់ធ្ងរដែលបណ្តាលមកពីការខ្វះស្បៀងអាហារ ទឹក និងសម្ភារអនាម័យ។ គ្រួសារខ្លះត្រូវបានបំបែកចេញពីគ្នា និងខ្លះបានស្លាប់នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅនោះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កាលៈទេសៈដែលបានធ្វើឱ្យប៉ះពាល់ដល់ប្រជាជនជាច្រើននេះ ពិតជាមានលក្ខណៈគ្រប់គ្រាន់អាចចាត់ជាបទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

## ១.៣.៤.ការធ្វើទុក្ខបុកម្នេញ

54. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ ព្រមទាំងនៅទួលពោធិ៍ជ្រៃ។ ជនរងគ្រោះនៃបទល្មើសនេះគឺ ជាទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរព្រមទាំងជនស៊ីវិលដែលរស់នៅក្នុងទីក្រុងភ្នំពេញក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ដែលហៅថា "ប្រជាជន ១៧ មេសា" ឬ"ប្រជាជនថ្មី"។

### ១.៣.៤.១.និយមន័យនៃការធ្វើទុក្ខបុកម្នេញ

55. ជនជាប់ចោទ បានជំទាស់ទៅនឹងការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការធ្វើទុក្ខបុកម្នេញ។ យោងតាមអង្គជំនុំជម្រះសាលាដំបូង ក្រុមដែលជាកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញអាចរួម

បញ្ចូលផងដែរនូវក្រុមដែលសមាជិករបស់ខ្លួនពុំប្រកាន់ទស្សនៈនយោបាយរួមណាមួយ ប៉ុន្តែត្រូវបានធ្វើទុក្ខបុកម្នេញដោយសារការជំរុញទឹកចិត្ត ឬកម្មវិធីនយោបាយរបស់ចារី។

56. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសទាក់ទងទៅនឹងបញ្ហានេះទេ។ អង្គជំនុំជម្រះរំឭកពីការយល់ឃើញរបស់ខ្លួនក្នុង*រឿងក្តី ឌុច* ថា ជនរងគ្រោះត្រូវតែជាក្រុមដែលអាចកំណត់បានច្បាស់លាស់គ្រប់គ្រាន់*ដោយចារី* ដោយផ្អែកលើមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា។ ជាពិសេស ក្រុមអាចក្លាយជាកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញ ព្រោះចារីបានកំណត់ពួកគេជាមុនថា ជាអ្នកប្រឆាំងសក្តានុពល ឬជាឧបសគ្គចំពោះការអនុវត្តកម្មវិធីនយោបាយ។

### ១.៣.៤.២.“ប្រជាជនថ្មី” គឺជាក្រុមដែលអាចកំណត់បានច្បាស់លាស់គ្រប់គ្រាន់

57. ជនជាប់ចោទបានលើកឡើងបន្ថែមទៀតថា “ប្រជាជនថ្មី” ពុំមែនជាក្រុមដែលអាចកំណត់បានច្បាស់លាស់គ្រប់គ្រាន់ និងថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យពុំស៊ីសង្វាក់គ្នា។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងទាំងនេះឡើយ ដោយសារ“ប្រជាជនថ្មី” បានរួមបញ្ចូលអ្នកដែលកំពុងរស់នៅក្នុងទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដោយពុំគិតថា ពួកគាត់បានរស់នៅក្នុងទីក្រុងរយៈពេលយូរ ឬទើបតែមកស្នាក់នៅថ្មីៗនោះទេ។

### ១.៣.៤.៣.ការធ្វើទុក្ខបុកម្នេញក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ

58. អង្គជំនុំជម្រះតុលាការកំពូលពិចារណាបន្ថែមទៀតថា ប្រជាជនទីក្រុងភ្នំពេញទាំងមូលត្រូវបានដាក់ឱ្យស្ថិតក្រោមការផ្លាស់ទីលំនៅ (ដោយសារអ្នកទាំងអស់នេះ ត្រូវបានចាត់ទុកជា“ប្រជាជនថ្មី”)។ ទោះជាយ៉ាងណាក្តី នេះពុំមែនមានន័យថា ជាការកំណត់គោលដៅដោយមិនរើសមុខ និងមិនអាចចាត់ជាការធ្វើទុក្ខបុកម្នេញបាននោះទេ ពីព្រោះថា “ប្រជាជនថ្មី”ត្រូវបានកំណត់គោលដៅដោយសារពួកគេត្រូវបានសន្មត និងចាត់ទុកថា ជាតំណាងឱ្យក្រុមនោះ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ជនជាប់ចោទទាក់ទងនឹងបញ្ហានេះត្រូវបដិសេធចោល។

### ១.៣.៤.៤.ការធ្វើទុក្ខបុកម្នេញក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ

59. ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានភស្តុតាងបង្ហាញថា អ្នកដែលត្រូវបានជម្លៀសភាគច្រើនលើសលុប គឺជា“ប្រជាជនថ្មី”នោះទេ។ ដូច្នេះ ពុំបានបង្ហាញឱ្យឃើញថា ការផ្លាស់ទីលំនៅនេះគឺជាការរើសអើងនោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុង

ការយល់ឃើញថា ការធ្វើទុក្ខបុកម្នេញត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ។

### ១.៣.៥.ធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

60. អង្គជំនុំជម្រះតុលាការកំពូល បដិសេធទឡ្ហីករណ៍នៅក្នុងបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ចំពោះសំអាងហេតុលម្អិតសម្រាប់ការយល់ឃើញនេះ មាននៅក្នុងសាលដីកាពេញលេញ។

### ១.៤.ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល

61. បញ្ហាទាក់ទងទៅនឹងទឡ្ហីករណ៍អំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលគឺ ថាតើជនជាប់ចោទអាចដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើង ដែរ ឬយ៉ាងណា។

62. អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្រោមទម្រង់មូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម (ហៅថា សហឧក្រិដ្ឋកម្មរួមទម្រង់ I "JCE I") ព្រមទាំងទទួលខុសត្រូវចំពោះការរៀបចំផែនការ ការញុះញង់ ការជួយនិងជំរុញ និងចំពោះជនជាប់ចោទ នួន ជា តែម្នាក់ទាក់ទងទៅនឹងការបញ្ជានៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនេះ និងបានផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវរបស់ថ្នាក់លើ។

### ១.៤.១.សហឧក្រិដ្ឋកម្មរួម

63. ជនជាប់ចោទ បានលើកទឡ្ហីករណ៍មួយចំនួននៅក្នុងបណ្តឹងសាទុក្ខទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ខ្លួនដោយផ្អែកលើសហឧក្រិដ្ឋកម្មរួម។

#### ១.៤.១.១.អត្ថិភាពនៃការទទួលខុសត្រូវដោយផ្អែកលើសហឧក្រិដ្ឋកម្មរួមទម្រង់ I នៅក្នុងអំឡុងពេលដែលជាប់ពាក់ព័ន្ធ

64. ជាការកត់សម្គាល់ ជនជាប់ចោទបានជំទាស់ទៅនឹងអត្ថិភាពនៃការទទួលខុសត្រូវដោយផ្អែកលើសហឧក្រិដ្ឋកម្មរួមទម្រង់ I។ ជនជាប់ចោទបានលើកឡើងថា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានអត្ថិភាពនៅពេលនោះ ការទទួលខុសត្រូវ ត្រូវបានកម្រិតត្រឹមតែការរួមចំណែកនៅក្នុងឧក្រិដ្ឋកម្មជាក់លាក់ និងថា ត្រឹមតែការរួមចំណែកនៅក្នុងការអនុវត្តគោលបំណងរួម ពុំគ្រប់គ្រាន់ក្នុងការបង្កើតឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលឡើយ។

65. អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងនេះឡើយ។ បើទោះបីជាពាក្យ“សហឧក្រិដ្ឋកម្មរួម”ត្រូវបានបង្កើតឡើងដោយតុលាការ ICTY ក៏ដោយ ក៏សញ្ញាណមូលដ្ឋាននេះបានកើតមានរួចហើយនៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ។ ជាការកត់សម្គាល់ ក្រោយសង្គ្រាមលោកលើកទីពីរ ចារីត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋនានា ដែលខ្លួនពុំបានប្រព្រឹត្តដោយផ្ទាល់ឡើយ ដោយហេតុថា បទឧក្រិដ្ឋនេះមាននៅក្នុងគោលបំណងឧក្រិដ្ឋរួមដែលចារីបានរួមចំណែក។

66. អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា គោលបំណងរួមត្រូវតែមានចរិតលក្ខណៈជាបទល្មើស។ នេះមានន័យថា ជាការប្រព្រឹត្តបទឧក្រិដ្ឋមួយ ឬច្រើន ឬការអនុវត្តគោលបំណងរួមដែលត្រូវតែជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋមួយ ឬច្រើន។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើការបង្កើតរូបមន្តមួយដែលខុសប្លែកបន្តិចត្រង់ថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ ថាតើគោលបំណងរួមក្នុងចំណោមនោះ *បានបណ្តាលឱ្យ* មានការប្រព្រឹត្តបទឧក្រិដ្ឋ ដែរ ឬយ៉ាងណា។ នេះបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទឧក្រិដ្ឋដែលជាទូទៅបណ្តាលមកពីការអនុវត្តគោលបំណងរួម អាចដាក់ឱ្យជនជាប់ចោទទទួលខុសត្រូវបាន បើទោះបីជាបទឧក្រិដ្ឋនេះពុំមែនជាផ្នែកនៃគោលបំណងរួមក៏ដោយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នេះត្រូវចាត់ជាការទទួលខុសត្រូវមួយប្រភេទដែលជាការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ III ឬទម្រង់ទូលាយ។ ដូច្នេះ បញ្ហាគឺ ថាតើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានអត្ថិភាពក្នុងឆ្នាំ ១៩៧៥ ជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ ដែរ ឬយ៉ាងណា ចំពោះបទឧក្រិដ្ឋដែលកើតចេញតែពីការអនុវត្តគោលបំណងរួម ប៉ុន្តែពុំមាននៅក្នុងគោលបំណងរួមនោះ។

67. ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ និងយល់ស្របជាមួយនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលថា ការទទួលខុសត្រូវនេះ ពុំមានអត្ថិភាពនៅពេលនោះឡើយ។ ដោយបានពិចារណាលើយុត្តិសាស្ត្រពាក់ព័ន្ធ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានបានថា ពិតជាពុំមានមូលដ្ឋានតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិសម្រាប់ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ដែលពុំមាននៅក្នុងគោលបំណងរួមប្រាកដមែន។

68. យោងតាមការយល់ឃើញនេះ តម្រូវឱ្យមានការបង្ហាញពីលក្ខណៈវិនិច្ឆ័យដើម្បីកំណត់ ថាតើបទឧក្រិដ្ឋណាខ្លះដែលមាននៅក្នុងគោលបំណងរួមនេះ។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គោលបំណងរួម“ត្រូវចាត់ទុកជា”ការប្រព្រឹត្តបទឧក្រិដ្ឋ នៅពេលដែលបទឧក្រិដ្ឋនេះស្ថិតក្នុងចំណោមគោលដៅចម្បងនៃគោលបំណងរួម។ ផ្ទុយទៅវិញ គោលបំណងរួម“ជាប់ពាក់ព័ន្ធ”

ទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ នៅពេលដែលបទឧក្រិដ្ឋនោះពុំមែនជាគោលដៅផ្ទាល់នៃកិច្ចប្រតិបត្តិការ ប៉ុន្តែត្រូវបានរកឃើញថា ជាមធ្យោបាយដើម្បីសម្រេចគោលដៅចុងក្រោយមួយ។ បញ្ហា ថាតើបទឧក្រិដ្ឋ មានក្នុងគោលបំណងរួម ដែរ ឬយ៉ាងណានោះ ជាចម្បង គឺជាបញ្ហានៃអង្គហេតុ ឧទាហរណ៍ដូចជា កត្តាពាក់ព័ន្ធនានាដែលនឹងក្លាយជាគោលដៅទូទៅនៃគោលបំណងរួម និងភវនីយភាពដែលគោលបំណងរួមនេះអាចសម្រេចបាន លុះត្រាតែមានការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។

69. សរុបសេចក្តីមក អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការកំណត់និយមន័យអំពីធាតុផ្សំផ្នែកច្បាប់នៃការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម។ បញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការវាយតម្លៃលើបញ្ហា ថាតើធាតុផ្សំនៃការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម ប្រសិនបើបកស្រាយឱ្យត្រឹមត្រូវនោះ បានបំពេញតាមលក្ខខណ្ឌ ដែរ ឬយ៉ាងណា។

### ១.៤.១.២.ការកំណត់និយមន័យនៃគោលបំណងរួម

70. ទាក់ទងទៅនឹងអំណះអំណាងបន្ទាប់ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា ការទទួលខុសត្រូវក្រោមទម្រង់ I នៃសហឧក្រិដ្ឋកម្មរួមតម្រូវថា គោលបំណងរួមត្រូវតែមានចរិតជាបទ*ល្មើស*។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាប់ចោទបានយល់ស្របទៅនឹងគោលបំណងរួមដែលអង្គជំនុំជម្រះចាត់ទុកថា ពុំមានចរិតជាបទល្មើសនោះ គឺការកសាងបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សក្នុងប្រទេសកម្ពុជា។

71. ទោះជាយ៉ាងណាក្តី គោលបំណងរួមនេះត្រូវតែពិនិត្យមើលនៅក្នុងបរិបទនៃគោលនយោបាយខ្មែរក្រហមក្នុងការផ្លាស់ទីលំនៅប្រជាជន និងគោលនយោបាយកំណត់គោលដៅលើទាហាននៃរបបសាធារណរដ្ឋខ្មែរ។ យោងតាមអង្គជំនុំជម្រះសាលាដំបូង គោលនយោបាយទាំងនេះត្រូវបានប្រើប្រាស់ដើម្បីជំរុញបដិវត្តន៍សង្គមនិយមក្នុងប្រទេសកម្ពុជាឱ្យទទួលបានផ្លែផ្កា។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ថា គោលនយោបាយទាំងនេះជាក់ស្តែង គឺជា*ផ្នែក*នៃគោលបំណងរួមក៏ដោយ ក៏នៅតែមានភាពច្បាស់លាស់ថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកគោលនយោបាយនេះ ជាមធ្យោបាយសម្រាប់កសាងបដិវត្តន៍សង្គមនិយម។ ដូច្នេះ បើទោះបីជាការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអាចសន្មតថា ខ្វះភាពជាក់លាក់ក៏ដោយ ក៏នៅតែច្បាស់លាស់ថា មានទិដ្ឋភាពល្មើសនៃគោលនយោបាយទាំងពីរដែលជាស្នូលនៃសំណុំរឿង ០០២/០១។

72. យោងតាមហេតុផលនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ជនជាប់ចោទដែលថា គោលបំណងរួមដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញនេះពុំមែនជាបទល្មើស ដូច្នេះពុំអាចបង្ហាញថា មានការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមនោះឡើយ។

### ១.៤.១.៣.អត្ថិភាព និងខ្លឹមសារនៃគោលនយោបាយផ្លាស់ទីលំនៅប្រជាជន

73. ទស្សីករណ៍នៃបណ្តឹងសាទុក្ខមួយចំនួនបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអត្ថិភាព និងខ្លឹមសារនៃគោលនយោបាយផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានាទៅកាន់ទីជនបទ និងពីតំបន់មួយទៅតំបន់មួយផ្សេងទៀត។

74. ទាក់ទងទៅនឹងគោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានា អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសណាមួយ នៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គោលនយោបាយត្រូវបានបង្ហាញឱ្យឃើញក្នុងចំណោមនោះ តាមរយៈលំនាំស៊ីសង្វាក់គ្នានៃការជម្លៀសប្រជាជន ជាពិសេសដោយសារអង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ថា ការផ្លាស់ទីលំនៅទាំងអស់នេះ បានធ្វើឡើងតាមវិធីសាស្ត្រដូចៗគ្នានៅក្នុងប្រតិបត្តិការនោះឡើយ។

75. ទាក់ទងទៅនឹងគោលនយោបាយផ្លាស់ទីលំនៅប្រជាជនពីតំបន់មួយទៅតំបន់មួយផ្សេងទៀត អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំណះអំណាងរបស់ជនជាប់ចោទពុំមានមូលដ្ឋានគ្រប់គ្រាន់ឡើយ ហើយទាក់ទងទៅនឹងបញ្ហានេះ មានពន្យល់លម្អិតនៅក្នុងសាលដីកាពេញលេញ។

### ១.៤.១.៤.ឧក្រិដ្ឋកម្មដែលមាននៅក្នុងគោលបំណងរួមទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ

76. បញ្ហាបន្ទាប់ដែលត្រូវដោះស្រាយគឺ បទឧក្រិដ្ឋណាខ្លះដែលជាក់ស្តែងមាននៅក្នុងគោលបំណងរួមទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ។

77. សេចក្តីសង្ខេបនេះ ផ្តោតតែលើការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងទៅនឹងបទមនុស្សឃាត ដោយសារបទចោទនេះមានភាពចម្រូងចម្រាសខ្លាំង។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គោលបំណងរួមមានរួមបញ្ចូលការសម្លាប់អ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ និងមានការជាប់ពាក់ព័ន្ធទៅនឹងការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌ ដែលបានធ្វើឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន និងការសម្លាប់ជនស៊ីវិល និងអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ។ នេះគឺដោយសារ ក្នុងកាលៈទេសៈនោះ សមាជិកនៃសហឧក្រិដ្ឋកម្មរួមបានដឹងអំពីលក្ខខណ្ឌចំពោះអ្នកដែលត្រូវជម្លៀសនឹងត្រូវទទួលរង និងដឹងថា អ្នកដែលងាយទទួលរងគ្រោះបំផុតទំនងជានឹងស្លាប់

ដោយសារលក្ខខណ្ឌនេះ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការផ្លាស់ទីលំនៅ គឺជាប់ពាក់ព័ន្ធទៅនឹងប្រជាជនក្នុងទីក្រុងភ្នំពេញទាំងមូលដែលកើតឡើងក្នុងរយៈពេលខ្លី និងក្នុងរដូវប្រាំងដែលក្ដៅបំផុត។

78. ទាក់ទងទៅនឹងការសម្លាប់ជនស៊ីវិល និងទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានធ្វើឡើងក្នុងរយៈពេលមួយយ៉ាងខ្លី និងតាមរយៈកងទ័ពប្រដាប់ដោយអាវុធធុនធ្ងន់។ កាលៈទេសៈនេះបង្ហាញឱ្យឃើញដោយប្រយោលថា គោលបំណងរួមមានរួមបញ្ចូលការរំពឹងទុកថា នឹងប្រើអំពើហិង្សាដល់អាយុជីវិតពីសំណាក់កងទ័ពដែលទទួលបានកាតព្វកិច្ចក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ប្រសិនបើមានការប្រឆាំងការចចេសរឹងរូសណាមួយនោះ។ នេះគឺជាករណីដែលពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហា ថាតើមានការដាក់បទបញ្ជាជាក់លាក់ឱ្យសម្លាប់ ដែរ ឬយ៉ាងណា និង ថាតើនរណាជាអ្នកចេញបទបញ្ជានេះ ព្រមទាំង ថាតើបទបញ្ជានេះត្រូវបានចេញចំពោះតែកងទ័ពនៅក្រោមមេបញ្ជាការមួយចំនួន ដែរ ឬយ៉ាងណានោះឡើយ។

79. បញ្ហាបន្ទាប់ទៀតគឺ ថាតើការធ្វើមនុស្សឃាតស្ថិតក្នុងចំណោមបទឧក្រិដ្ឋដែលមាននៅក្នុងគោលបំណងរួម ដែរ ឬយ៉ាងណា ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ។ ផ្អែកលើកាលៈទេសៈនៃការផ្លាស់ទីលំនៅប្រជាជននេះ ពុំមានការបង្ហាញថា មានគោលនយោបាយផ្ដល់ការយកចិត្តទុកដាក់គ្រប់គ្រាន់ចំពោះអ្នកដែលត្រូវបានជម្លៀស ឬការពារពួកគេពីការរំលោភបំពាននានានោះឡើយ។ អាស្រ័យហេតុនេះ ការស្លាប់ដែលបានកើតឡើងចំពោះអ្នកដែលត្រូវបានជម្លៀសនោះ ហើយទំនងជាជាប់ពាក់ព័ន្ធទៅនឹងសមាជិកនៃសហឧក្រិដ្ឋកម្មរួមក្នុងការអនុវត្តគោលបំណងរួមនោះ។ ដូច្នេះ គោលនយោបាយផ្លាស់ទីលំនៅប្រជាជន មានរួមបញ្ចូលដោយប្រយោលនូវបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

### ១.៤.២.អត្ថិភាព និងខ្លឹមសារនៃគោលនយោបាយកំណត់គោលដៅ

80. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខ្មែរក្រហមមានគោលនយោបាយកំណត់គោលដៅលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលគោលនយោបាយនេះពាក់ព័ន្ធទៅនឹងការសម្លាប់នៅទួលពោធិ៍ជ្រៃ។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសេចក្ដីថ្លែងការណ៍របស់ខ្មែរក្រហម និងបទបញ្ជា ព្រមទាំងអត្ថិភាពនៃលំនាំស៊ីសង្វាក់គ្នានៃការសម្លាប់។ ជនជាប់ចោទបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងបញ្ហានេះ។

81. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ទាក់ទងទៅនឹងលំនាំនៃការសម្លាប់ដែលមានអត្ថិភាពនៅមុនខែ មេសា ឆ្នាំ ១៩៧៥ អង្គជំនុំជម្រះសាលាដំបូងបានផ្តោតជាសំខាន់ទៅលើការសម្លាប់នៅឧដុង្គក្នុងឆ្នាំ ១៩៧៤។ ទោះជាយ៉ាងណាក្តី ដូចបានពន្យល់នៅក្នុងសំអាងហេតុនៃសាលដីការបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ភស្តុតាងក្នុងសំណុំរឿងមានលក្ខណៈខ្សោយពេកពុំអាចគាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនេះបានឡើយ។ ភស្តុតាងដទៃទៀតនៃការសម្លាប់នៅមុនឆ្នាំ ១៩៧៥ ក៏មានលក្ខណៈខ្សោយផងដែរ។

82. ចំពោះភស្តុតាងនៃការសម្លាប់នៅក្នុងអំឡុងពេលភ្លាមៗ មុន និងក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាទូទៅក៏មានកម្រិតខ្សោយដែរ លើកលែងតែហេតុការណ៍ពីរ ឬបីប៉ុណ្ណោះ។ ប្រហាក់ប្រហែលគ្នានេះដែរ ទាក់ទងទៅនឹងការសម្លាប់នៅចុងឆ្នាំ ១៩៧៥ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើភស្តុតាងដែលជាញឹកញាប់មានកង្វះព័ត៌មានលម្អិត និងជាចម្បង ជាចម្លើយក្រៅតុលាការដែលពុំមានការបញ្ជាក់បន្ថែមឡើយ។

83. អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើភស្តុតាងដទៃទៀតប្រហាក់ប្រហែលគ្នានេះដែរ ដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើនោះ ដូចជាសុន្ទរកថា សេចក្តីថ្លែងការណ៍អំពីគោលនយោបាយ និងសេចក្តីណែនាំនានារបស់ខ្មែរក្រហម។

84. សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងពុំមានលក្ខណៈគ្រប់គ្រាន់ ក្នុងការផ្តល់មូលដ្ឋានគាំទ្រសមហេតុផលដល់ការយល់ឃើញដែលថា នៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ មានគោលនយោបាយសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ។ ភស្តុតាងភាគច្រើន គឺជាចម្លើយក្រៅតុលាការដែលមានតម្លៃភស្តុតាងទាប។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើភស្តុតាងមួយចំនួនដែលចោទជាបញ្ហាដល់អត្ថិភាពនៃគោលនយោបាយជារួមក្នុងការសម្លាប់។ អង្គជំនុំជម្រះតុលាការកំពូលរំឭកនៅក្នុងបរិបទនេះថា ដោយសារលទ្ធផលនៃការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ទើបវិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានរឹតត្បិតត្រង់ចំណុចពាក់ព័ន្ធទៅនឹងគោលនយោបាយកំណត់គោលដៅចំពោះព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃដែលបានកើតឡើងនៅក្នុងចុងខែ មេសា ឆ្នាំ ១៩៧៥។ ជាលទ្ធផលបានធ្វើឱ្យការពិចារណាទទួលរងការប៉ះពាល់ដោយសារការកម្រិតពេលវេលានេះ ដែលបណ្តាលឱ្យភស្តុតាងមួយផ្នែកធំលែងមានភាពពាក់ព័ន្ធទៅនឹងពេលវេលា ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងពុំអាចបង្ហាញ ថាតើមូលហេតុអ្វីបានជាសេចក្តីណែនាំនានាដាក់ចេញក្នុងឆ្នាំ ១៩៧៦ និងក្រោយមក បែរជា បញ្ជាក់ពីអត្ថិភាពគោលនយោបាយក្នុងខែ មេសា ឆ្នាំ ១៩៧៥ ទៅវិញ។

85. យោងតាមហេតុផលខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ផ្អែកលើភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ពុំមានលក្ខណៈសមហេតុផលក្នុងការយល់ឃើញថា គោលនយោបាយក្នុងការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មានអត្ថិភាពនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃទេ។ អាស្រ័យហេតុនេះ ជនជាប់ចោទពុំអាចដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃឡើយ។

## ១.៤.៣.បទដ្ឋានគតិយុត្តទាក់ទងទៅនឹងការរួមចំណែកនៅក្នុងគោលបំណងរួម

86. ទាក់ទងទៅនឹងបទដ្ឋានគតិយុត្តទាក់ទងទៅនឹងការរួមចំណែកនៅក្នុងគោលបំណងរួម ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញថា ខ្លួនមានការរួមចំណែកក្នុងការប្រព្រឹត្តអំពើល្មើស ប៉ុន្តែគ្រាន់តែថា មានការជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពជាទូទៅក្នុងគោលបំណងកសាងបដិវត្តន៍សង្គមនិយមនៅកម្ពុជាប៉ុណ្ណោះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងជាទូទៅបានបញ្ជាក់អំពីបទដ្ឋានគតិយុត្តត្រឹមត្រូវ ត្រង់ថា ការរួមចំណែករបស់ជនជាប់ចោទត្រូវតែ"សំខាន់ ប៉ុន្តែពុំចាំបាច់សំខាន់រហូតដល់ខ្វះមិនបាននោះទេ"។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញត្រឹមត្រូវផងដែរថា ការរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួមអាចធ្វើឡើងតាមទម្រង់ជាច្រើន។ បើសូម្បីសកម្មភាពដែល*តាមសេចក្តីបញ្ជាក់ដំបូង*ពុំជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋក៏ដោយ ក៏អាចយកមកពិចារណាបានដែរ នៅពេលកំណត់ ថាតើជនជាប់ចោទបានរួមចំណែកយ៉ាងសំខាន់ ដែរ ឬយ៉ាងណានោះ។ អាស្រ័យហេតុនេះ ការកំណត់ជានិច្ចកាលគប្បីផ្អែកលើការវាយតម្លៃរាល់សកម្មភាពទាំងអស់របស់ជនជាប់ចោទដែលអង្គជំនុំជម្រះយល់ឃើញថា មានអត្ថិភាពនោះ។

87. សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសឡើយ ក្នុងការពិចារណាលើសកម្មភាពរបស់ជនជាប់ចោទ ដែលតាមរូបភាពខាងក្រៅ ពុំឃើញមានគោលដៅប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ឡើយ។

## ១.៤.៤.ការរួមចំណែករបស់ នួន ជា នៅក្នុងការអនុវត្តគោលបំណងរួម

88. អង្គជំនុំជម្រះសាលាដំបូងបានកំណត់ការរួមចំណែករបស់ នួន ជា ជាពីរប្រភេទក្នុងការអនុវត្តគោលបំណងរួម។ ទីមួយ គឺការជាប់ពាក់ព័ន្ធរបស់គាត់នៅក្នុងការរៀបចំផែនការនៃគោលបំណងរួម និងទីពីរ គឺតួនាទីរបស់គាត់នៅក្នុងសកម្មភាពទាក់ទងទៅនឹងការឃោសនា ការបណ្តុះបណ្តាលអប់រំជាសាធារណៈ។ នួន ជា បានលើកទឡ្ហីករណ៍មួយចំនួននៅក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងការយល់ឃើញនេះ។

89. អង្គជំនុំជម្រះតុលាការកំពូលបដិសេធទឡ្ហីករណ៍មួយចំនួននៅក្នុងបណ្តឹងសាទុក្ខ ដោយសារពុំមានសក្តានុពលអាចនាំឱ្យមោឃៈសាលក្រម ដែលមានដូចជា ការជំទាស់ទៅនឹងការដាក់ងារជាបងធំទីពីរ។ ទាក់ទងទៅនឹងទឡ្ហីករណ៍ដទៃទៀតនៅក្នុងបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នួន ជា បានត្រឹមតែផ្តល់ការបកស្រាយមួយបែបផ្សេងទៀតទៅលើភស្តុតាងប៉ុណ្ណោះ។ ជាពិសេស បញ្ហានេះពាក់ព័ន្ធទៅនឹងការយល់ឃើញដែលថា គាត់មានឥទ្ធិពលខ្លាំងលើគោលនយោបាយយោធា និងថា គាត់មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចចុងក្រោយនៅក្នុងបក្ស ដូច ប៉ុល ពត ដែរ។

90. ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញដោយសមហេតុផលថា នួន ជា ទទួលបន្ទុកខាងដាក់វិន័យរបស់បក្សឡើយ។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា កំហុសនេះពុំមានឥទ្ធិពលលើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា នួន ជា បានរួមចំណែកយ៉ាងសំខាន់នៅក្នុងការអនុវត្តគោលបំណងរួមនោះឡើយ។

## ១.៤.៥.ការរួមចំណែករបស់ ខៀវ សំផន នៅក្នុងការអនុវត្តគោលបំណងរួម

91. ទាក់ទងទៅនឹងការរួមចំណែករបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានកំណត់សកម្មភាពដូចតទៅ៖ ទីមួយ ខៀវ សំផន បានចូលរួមកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម និងសមាជបក្ស ព្រមទាំងកិច្ចប្រជុំផ្សព្វផ្សាយគោលនយោបាយខ្មែរក្រហមទៅដល់កម្មាភិបាលថ្នាក់ក្រោម។ ទីពីរ ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចការសេដ្ឋកិច្ចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទីបី គាត់បានធ្វើសេចក្តីថ្លែងជាសាធារណៈគាំទ្រគោលបំណងរួម និងគោលនយោបាយរបស់ខ្មែរក្រហម។ ចុងក្រោយ គាត់បានបម្រើការជាអ្នកការទូតក្នុងការកៀងគរការគាំទ្រពីខាងក្រៅខ្មែរក្រហម។ ខៀវ សំផន បានចោទប្រកាន់កំហុសមួយចំនួននៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង។

92. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការយល់ឃើញភាគច្រើននេះត្រូវបានធ្វើឡើងដោយសមហេតុផល។ ទោះជាយ៉ាងណាក្តី ជាការពុំសមហេតុផលក្នុងការយល់ឃើញថា ខៀវ សំផន បានចូលរួមកិច្ចប្រជុំក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ ដែលក្នុងពេលនោះមានការពិភាក្សាអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញឡើយ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់ពីមូលហេតុដែលខ្លួនបានសម្រេចបដិសេធសក្ខីកម្មលម្អិតរបស់ នួន ជា ដែលបានលើកឡើងផ្ទុយពីការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង។ ប្រហាក់ប្រហែលគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងក៏មានកំហុសដែរ ក្នុងការចាត់ទុកសុន្ទរកថាដែលបានធ្វើឡើងក្នុងឆ្នាំ ១៩៧៦ ថា ជារបស់ ខៀវ សំផន។

93. បើទោះបីជាការយល់ឃើញនេះមានកំហុសក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សេចក្តីសន្និដ្ឋានទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការរួមចំណែករបស់ ខៀវ សំផន ជាការសមហេតុផល ដោយពិចារណាលើសកម្មភាពទាំងមូលរបស់គាត់។

### ១.៤.៦.ការយល់ឃើញថា ប.ក.ក. ជាបក្សដែលមានលក្ខណៈរួបរួម និងមានឋានានុក្រម និងថា កងទ័ពដែលបានចូលរួមក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មានលក្ខណៈរួបរួមគ្នា

94. ជនជាប់ចោទបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ប.ក.ក. ជាបក្សដែលមានលក្ខណៈរួបរួម និងមានឋានានុក្រម ដោយសារតែ តាំងពីដំបូងមក បក្សនេះបានបំបែកជាក្រុមតូចៗដ៏មានអំណាច ដែលក្រោយមកក៏បានធ្វើការបះបោរប្រឆាំងនឹងបក្ស។ ជនជាប់ចោទបានលើកឡើងថា ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចសន្និដ្ឋានបានថា ប៉ុល ពត និង នួន ជា បានរួមចំណែកក្នុងគោលបំណងរួមជាមួយនឹងមេដឹកនាំភូមិភាគមួយចំនួនដែលធ្វើការបះបោរប្រឆាំងនឹងពួកគាត់បាននោះឡើយ។

95. អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងនេះឡើយ។ អង្គជំនុំជម្រះរំឭកថា ជនជាប់ចោទត្រូវបានរកឃើញថា ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដោយផ្អែកលើសហឧក្រិដ្ឋកម្មរួម។ អាស្រ័យហេតុនេះ ប្រសិនបើថា ផែនការសម្លាប់របស់មេដឹកនាំភូមិភាគមួយចំនួនមានអត្ថិភាពក៏ដោយ ក៏ពុំមែនមានន័យថា បទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានដាក់ឱ្យទទួលខុសត្រូវនោះ ពុំអាចដាក់ទៅលើសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមបាននោះទេ ដរាបណានៅតែមានការបង្ហាញថា មានគោលបំណងរួម ហើយបទឧក្រិដ្ឋ គឺជាផ្នែកនៃគោលបំណងរួមនេះ។

### ១.៤.៧.កំហុសអង្គច្បាប់ទាក់ទងទៅនឹងចេតនាតម្រូវ

96. ទាក់ទងទៅនឹងចេតនាតម្រូវសម្រាប់ការទទួលខុសត្រូវតាមទម្រង់សហឧក្រិដ្ឋកម្មរួម ខៀវ សំផន បានលើកឡើងថា បទដ្ឋានត្រឹមត្រូវ គឺ "ចេតនាធ្វើឱ្យគោលបំណងរួមមានប្រសិទ្ធភាព"។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង គឺជាការត្រឹមត្រូវដែលថា ចេតនាត្រូវគ្របដណ្តប់ទាំងគោលបំណងរួម ទាំងបទឧក្រិដ្ឋនានាដែលមានក្នុងនោះ។

97. ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការអនុវត្តបទដ្ឋានកម្រិតទាប ព្រោះអង្គជំនុំជម្រះបានវាយតម្លៃលើបញ្ហា ថាតើគាត់បានដឹងអំពីភាវនីយភាពខ្ពស់នៃការប្រព្រឹត្តបទឧក្រិដ្ឋ ដែរ ឬយ៉ាងណា។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "*ភាវនីយភាពខ្ពស់*" គឺពុំមែនជាបទដ្ឋានត្រឹមត្រូវនោះទេ។ ទោះជាយ៉ាងណាក្តី បទដ្ឋានត្រឹមត្រូវ

ចាំបាច់ត្រូវកំណត់ដោយផ្អែកលើបទឧក្រិដ្ឋជាក់លាក់ដែលរងការចោទប្រកាន់នេះ។ ជាឧទាហរណ៍ ចំពោះបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លក្ខខណ្ឌតម្រូវនៃធាតុផ្សំអត្តនោម័ត គឺចេតនាផ្ទាល់ ឬ*ចេតនាប្រយោល*។ ដូច្នេះ ប្រសិនបើអំពើមនុស្សឃាតត្រូវបានប្រព្រឹត្តឡើងតាមរយៈសហឧក្រិដ្ឋកម្មរួម នេះជាការគ្រប់គ្រាន់ក្នុងការបង្ហាញថា ជនជាប់ចោទបានដឹងថា ការស្លាប់នឹងកើតមានដោយសារផលវិបាកនៃការអនុវត្តគោលបំណងរួម ប៉ុន្តែនៅតែបន្តអនុវត្តដោយពុំគិតពីអ្វីកើតឡើង និងបានទទួលយកការស្លាប់ដែលអាចកើតមាននោះ។ អាស្រ័យហេតុនេះ ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើបទដ្ឋាន“ភាវនីយភាពខ្ពស់”នេះ តាមធម្មតាពុំមែនជាកំហុស ប៉ុន្តែអាស្រ័យលើបទឧក្រិដ្ឋដែលពាក់ព័ន្ធនោះ។

### ១.៤.៨.ចេតនារបស់ នួន ជា

98. មានភាពច្បាស់លាស់ថា នួន ជា បានប្រព្រឹត្តដោយចេតនាផ្ទាល់ ទាក់ទងទៅនឹងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ជាការពិត នួន ជា ក៏បានទទួលស្គាល់ថា គាត់បានចូលរួមនៅក្នុងការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

99. ទាក់ទងទៅនឹងអំពើមនុស្សឃាត អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទាក់ទងទៅនឹង“ជនមហាក្បត់” នួន ជា បានទទួលស្គាល់ជាក់លាក់ថា គាត់មានចេតនាសម្លាប់អ្នកទាំងនេះ។ ទាក់ទងទៅនឹងការស្លាប់ និងការសម្លាប់ដទៃទៀតដែលបានកើតឡើងនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គាត់បានប្រព្រឹត្ត*ដោយចេតនាប្រយោល* ដោយផ្អែកលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការដឹងរបស់គាត់អំពីកាលៈទេសៈដែលក្នុងនោះមានការផ្លាស់ទីលំនៅប្រជាជន។

### ១.៤.៩.ចេតនារបស់ ខៀវ សំផន

100. ខៀវ សំផន បានជំទាស់ផងដែរទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីចេតនាប្រព្រឹត្តបទឧក្រិដ្ឋរបស់គាត់។ ជាពិសេស គាត់បានអះអាងថា បក្សបានធ្វើប្រតិបត្តិការក្រោមគោលការណ៍រក្សាការសម្ងាត់ ដែលនេះបានរាំងរូបគាត់មិនឱ្យដឹងអំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តនោះ។

101. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ពុំបានលើកមូលដ្ឋានគាំទ្រអំណះអំណាងរបស់ខ្លួនឡើយ ដោយហេតុថា គាត់ពុំបានពិនិត្យលើសំអាងហេតុយ៉ាងទូលំទូលាយរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់អំពីបទឧក្រិដ្ឋ និងពុំបានផ្តល់មូលដ្ឋានគាំទ្រអំពីផលប៉ះពាល់នៃកំហុសចំពោះការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ខ្លួនឡើយ។

102.ខៀវ សំផន បានជំទាស់លើការយល់ឃើញជាច្រើនទៀតរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងចេតនារបស់គាត់។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភាគច្រើននៃអំណះអំណាងរបស់គាត់ពុំបានបង្ហាញអំពីភាពមិនសមហេតុផលនោះឡើយ។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងមានកំហុសត្រង់ថា ខ្លួនបានសំអាងតែទៅលើវត្តមានរបស់គាត់នៅក្នុងសមាជពិសេសថ្នាក់ជាតិដែលបានធ្វើឡើងនៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ ប៉ុណ្ណោះ។

103.ទោះជាយ៉ាងណាក្ដី បើទោះបីជាការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមួយចំនួនមានកំហុសក៏ដោយ ក៏ពុំមានភាពគ្រប់គ្រាន់ដែលអាចចោទជាបញ្ហាដល់សេចក្ដីសន្និដ្ឋានទូទៅដែលថា ខៀវ សំផន បានប្រព្រឹត្តដោយចេតនាតម្រូវនោះឡើយ។

### ១.៤.១០.ទម្រង់ដទៃទៀតនៃការទទួលខុសត្រូវ

104.អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋដែលអង្គជំនុំជម្រះបានរកឃើញថា មានអត្ថិភាពដោយផ្អែកលើការទទួលខុសត្រូវចំពោះការរៀបចំផែនការ ការញុះញង់ ការជួយនិងជំរុញ និងចំពោះជនជាប់ចោទ នួន ជា តែម្នាក់ទាក់ទងទៅនឹងការបញ្ជានៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនេះ។ ជនជាប់ចោទបានលើកទឡ្ហីករណ៍ជាច្រើននៅក្នុងបណ្ដឹងសាទុក្ខទាក់ទងទៅនឹងបញ្ហានេះ។ ទោះជាយ៉ាងណាក្ដី សំអាងហេតុទាក់ទងនឹងបញ្ហានេះ មានពន្យល់ពេញលេញនៅក្នុងសាលដីកា និងដោយសារមានការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទក្នុងសហឧក្រិដ្ឋកម្មរួមរួចហើយ ដូច្នេះអង្គជំនុំជម្រះតុលាការកំពូលពុំចាំបាច់ប្រកាសទាក់ទងទៅនឹងទឡ្ហីករណ៍ទាំងនេះឡើយ។

### ១.៥.ការប្រកាសទោស

105.ខៀវ សំផន បានជំទាស់ជាពិសេសទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការប្រកាសទោសមកលើខ្លួន។

106.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំណះអំណាងរបស់ ខៀវ សំផន ពុំបានបង្ហាញអំពីកំហុសក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

107.ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើបញ្ហា ថាតើការដែលអង្គជំនុំជម្រះបានរកឃើញកំហុសនៅក្នុងសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទនោះ នាំឱ្យអង្គជំនុំជម្រះកែប្រែការប្រកាសទោសដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចនោះ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ភាព

ធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ គប្បីផ្ទុះបញ្ចាំងនៅក្នុងការប្រកាសទោសនេះ។ ដោយផ្អែកលើភាពធំធេងនៃបទឧក្រិដ្ឋ ការខ្វះការយកចិត្តទុកដាក់ទាំងស្រុងទៅលើវាសនាចុងក្រោយរបស់ប្រជាជនកម្ពុជា ជាពិសេសក្រុមដែលងាយទទួលរងគ្រោះបំផុត និងជាការពិត បទឧក្រិដ្ឋនេះពុំមែនជាហេតុការណ៍ដាច់ដោយឡែកឡើយ ប៉ុន្តែបានកើតឡើងក្នុងរយៈពេលយ៉ាងយូរ និងដោយសារតួនាទីយ៉ាងសំខាន់របស់ជនជាប់ចោទ ដែលនាំឱ្យអង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការផ្តន្ទាទោសជនជាប់ចោទម្នាក់ៗឱ្យជាប់ពន្ធនាគារអស់មួយជីវិត គឺជាការសមស្រប។ អាស្រ័យហេតុនេះ គប្បីតម្កល់ការប្រកាសទោសដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង។

## ២.បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

108.ខាងក្រោមនេះគឺជាសេចក្តីសង្ខេបការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

109.សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ III ពុំអាចអនុវត្តបាននៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក.។ សហព្រះរាជអាជ្ញាបានស្នើសុំ“ដំណោះស្រាយឱ្យធ្វើការប្រកាស”តែប៉ុណ្ណោះ និងទទួលស្គាល់ថា លទ្ធផលនៃបណ្តឹងសាទុក្ខរបស់ខ្លួនពុំមានឥទ្ធិពលលើការសម្រេចដាក់ពិរុទ្ធភាពជនជាប់ចោទឡើយ។ ទោះជាយ៉ាងណាក្តី ដើម្បីឱ្យបណ្តឹងសាទុក្ខអាចទទួលយកបាន បណ្តឹងសាទុក្ខនេះត្រូវតែលើកឡើងអំពីកំហុសអង្គច្បាប់ដែលនាំឱ្យមោឃៈសេចក្តីសម្រេច។ ក្នុងករណីដែលពុំមានការលើកឡើងបែបនេះទេ បណ្តឹងសាទុក្ខនេះពុំអាចទទួលយកបានឡើយ។ ទោះជាយ៉ាងណាក្តី បណ្តឹងសាទុក្ខដែលបានដាក់ដោយជនជាប់ចោទបានផ្តល់ឱកាសឱ្យអង្គជំនុំជម្រះតុលាការកំពូលពិចារណារួចហើយ ទៅលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម រួមទាំងទិដ្ឋភាពដែលជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងបញ្ហាដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា។

## ៣.ផ្នែកសម្រេចសេចក្តី

យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេចៈ**

**ដោយអនុលោមតាម** វិធាន ៤ (១)(ខ) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១៤ ថ្មី(១)(ខ) និងមាត្រា ៣៦ ថ្មីនៃច្បាប់ អ.វ.ត.ក. និង វិធាន ១១១ នៃវិធានផ្ទៃក្នុង

**បានកត់សម្គាល់**សារណាបណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សរនីមួយៗរបស់ភាគី និងអំណះអំណាងដែលបានលើកឡើងនៅក្នុងសវនាការនៅថ្ងៃទី ១៦ ដល់ ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦

**ទទួលយក**ផ្នែកខ្លះ និង **បដិសេធ**ផ្នែកខ្លះទៀតនៃបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន ដែល៖

**ពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ**

**បដិសេធ**ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង

**តម្កល់**ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទមនុស្សឃាត បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

**ពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ**

**បដិសេធ**ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទសម្លាប់រង្គាល និងបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

**តម្កល់**ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង**កែប្រែ**ប្រភេទគតិយុត្តនៃបទល្មើសដោយសម្រេច **ដាក់ពិរុទ្ធភាព**លើ នួន ជា និង ខៀវ សំផន ពីបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិវិញ។

**ពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ**

**បដិសធ**ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទសម្លាប់រង្គាល បទមនុស្សឃាត និងបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

**ប្រកាសតម្កល់**ការប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតលើ នួន ជា និង ខៀវ សំផន របស់អង្គជំនុំជម្រះសាលាដំបូង

**ប្រកាសបដិសេធ**បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាថា ពុំអាចទទួលយកបាន

**បង្គាប់**ថា នួន ជា និង ខៀវ សំផន ត្រូវស្ថិតក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក. រង់ចាំការរៀបចំរួចរាល់ ស្របតាមច្បាប់ នឹងត្រូវផ្ទេរទៅពន្ធនាគារដែលត្រូវអនុវត្តន៍ទោសនៅទីនោះ។

សាលដីកានេះប្រកាស នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ជាពីរភាសាដើមគឺភាសាខ្មែរនិងអង់គ្លេស ដោយបកប្រែជាភាសាបារាំង។




**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ

ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា

ទូរស័ព្ទ ០២៣ ៨៦១ ៥០០

ទូរសារ ០២៣ ៨៦១ ៥៥៥

គេហទំព័រ www.eccc.gov.kh


**សម្រាប់ចែកចាយដោយឥតគិតថ្លៃ-ហាមលក់**